# ដបទឹកដែលបែក

ឃាឌីស្រេកទឹក ។ តើសូហ្វៀអាចជួយបានដោយរបៀបណា ?

ដោយ ណូអែល ឡាមបឹត ជាំុស
( ផ្អែកទៅលើដំណើររឿងពិត )

*ដំណើររឿងនេះបានកើតឡើងនៅ សេរ៉ា ឡេអូន ។*

សូហ្វៀបានស្ដាប់ដោយយកចិត្តទុកដាក់នៅពេលដែលគ្រូរបស់នាងពន្យល់លំហាត់គណិតវិទ្យានៅលើក្ដារខៀន ។

គ្រូបានសួរថា « ដូច្នេះតើប្រាំបួនគុណនឹងបួនស្មើប៉ុន្មាន ? »

សូហ្វៀបានលើកដៃ ។ នាងបានឆ្លើយថា « សាមប្រាំមួយ » ។

គ្រូរបស់នាងញញឹម ។ « ត្រូវហើយ សូហ្វៀ ! »

ពេលរៀនចប់ហើយវាក៏ដល់ពេលទៅផ្ទះវិញ ។ សូហ្វៀបានដើរជាមួយមិត្តភក្តិរបស់នាង ។ ពួកគេទាំងអស់គ្នាបានទាញដបទឹករបស់ពួកគេដើម្បីផឹកទឹក ដែលនៅសល់ចុងក្រោយរបស់ពួកគេ ។ ថ្ងៃនោះក្ដៅណាស់ !



ប៉ុន្តែសូហ្វៀបានឃើញអ្វីមួយប្លែក ។ មិត្តរបស់នាងខាឌីមិនបានយកទឹកមកផឹកទេ ។ នាងដើរដោយស្ងៀមស្ងាត់តែឯង ។

« ឃាឌី ដបទឹករបស់ឯងនៅឯណា ? » សូហ្វៀបានសួរ ។ មនុស្សគ្រប់គ្នាតែងតែស្រេកទឹកនៅពេលដែលរៀនចប់ ។

ខាឌីតបថា « ខ្ញុំបានធ្វើបែកដបទឹកកាលពីម្សិលមិញ ហើយខ្ញុំមិនមានដបទឹកថ្មីនៅឡើយទេ » ។ « ដូច្នេះឥឡូវខ្ញុំមិនមានអ្វីដាក់ទឹកទៅសាលារៀនទេ » ។

សូហ្វៀសម្លឹងមើលដបទឹករបស់នាង ។ នាងប្រាថ្នាថានាងអាចចែករំលែកបាន ! ប៉ុន្តែទឹករបស់នាងបានអស់ហើយ ។

សូហ្វៀបានគិតអំពីដបទឹកដែលបែករបស់ខាឌីពេញមួយថ្ងៃ ។ វាមិនងាយស្រួលទេក្នុងការទទួលបានទឹកស្អាតនៅកន្លែងដែលពួកគេរស់នៅ ។ ក្មេងភាគច្រើនទទួលបានដបទឹកតែមួយប៉ុណ្ណោះដើម្បីប្រើពេញមួយឆ្នាំ ។ ពួកគេបានច្រកវាពីធុងទឹកស្អាតមកពីផ្ទះ ។ អ្នកអាចឈឺពីការផឹកទឹកផ្សេងទៀត ។ ប្រសិនបើខាឌីមិនមានដបទឹក នោះនាងមិនអាចយកទឹកពីផ្ទះទៅផឹកនៅសាលារៀនបានទេ ។

នៅព្រឹកស្អែកឡើងសូហ្វៀ បានគិតពីរបៀបដែលនាងអាចជួយ ខាឌីបាន ។ គ្រួសាររបស់សូហ្វៀមានដបទឹកដ័រដែលមានទឹកពេញ ។ សូហ្វៀបានបន្ថែមដបមួយទៀតទៅក្នុងកាបូបស្ពាយរបស់នាងជាមួយដបដែករបស់នាង ។ វាធ្វើឲ្យកាបូបនោះធ្ងន់ជាងមុនបន្តិច ប៉ុន្តែនាងមិនខ្វល់ពីរឿងនោះទេ ។

ពេលនាងទៅរៀននាងបានរកឃើញខាឌី ។

« ខាឌី ដបទឹករបស់ឯងនៅឯណា ? » សូហ្វៀបានសួរ ។

ខាឌីបានគ្រវីក្បាល សម្លឹងចុះក្រោម ។

សូហ្វៀបាននិយាយថា « មិនអីទេ » ។ « ខ្ញុំមានដបមួយឲ្យឯង ! »

នាងបានឲ្យដបទឹកទៅខាឌី។ ខាឌីញញឹម ។

« អរគុណសូហ្វៀ » ។ ខាឌីបានឱបមិត្តរបស់នាងយ៉ាងណែន ។

ក្នុងអំឡុងពេលរៀន ខាឌីបានផឹកដបទឹករបស់នាងជាមួយក្មេងៗផ្សេងទៀត ។ សូហ្វៀសប្បាយចិត្តណាស់ដែលបានឃើញមិត្តរបស់នាងមិនចាំបាច់ស្រេកទឹកទៀត ។

ជារៀងរាល់ថ្ងៃក្នុងសប្ដាហ៍នោះ សូហ្វៀបានយកដបទឹកមកលើសសម្រាប់មិត្តរបស់នាង ។ បន្ទាប់មកនៅព្រឹកមួយម្ដាយរបស់សូហ្វៀបានលើកកាបូបស្ពាយរបស់នាងឡើង ។

ម៉ាក់បាននិយាយថា « ហឺ » ។ « មានអារម្មណ៍ថាវាធ្ងន់ជាងធម្មតា » ។ នាងបានបើកកាបូបស្ពាយ ហើយទាញដបទឹកដែលលើសនោះមក ។

« សូហ្វៀតើកូនមានចេតនាដាក់ដបទឹកលើសទៅសាលារៀនឬ ? » ម៉ាក់បានសួរ

សូហ្វៀបានងក់ក្បាល ។ « ដបទឹករបស់ខាឌីបែក ហើយនាងមិនទាន់រកបានដបទឹកថ្មីទេ ។ ដូច្នេះនៅសាលារៀននាងអត់មានទឹកផឹកទេ » ។

« តើកូនដាក់ដបទឹកលើសឲ្យនាងតាំងពីពេលណាមក ? » ម៉ាក់បានសួរ

សូហ្វៀបាននិយាយថា « តែសប្ដាហ៍នេះប៉ុណ្ណោះ » ។ « ខ្ញុំមិនចង់ឲ្យខាឌីស្រេកទឹកទេ » ។

ម៉ាក់បានញញឹម ។ « វាជារឿងល្អណាស់កូន ដែលចេះគិតពីមិត្តរបស់កូន ។ នោះគឺជាអ្វីដែលព្រះយេស៊ូវនឹងធ្វើ ។ ម៉ាក់សប្បាយចិត្តណាស់ដែលឃើញកូនធ្វើជាមនុស្សដូចជាព្រះយេស៊ូវ » ។

ម៉ាក់បានឱបសូហ្វៀ ។ « ហើយម៉ាក់គិតថា ម៉ាក់ដឹងពីវិធីមួយទៀតដែលយើងអាចជួយនាងបាន » ។

ម៉ាក់បានឲ្យដបទឹកដែកមួយទៅសូហ្វៀ ។ « ចូរឲ្យដបនេះទៅមិត្តកូនជំនួសវិញ ដូច្នេះនាងអាចបន្តប្រើវាឡើងវិញបាន ។ វិធីនេះកូនមិនចាំបាច់យកដបប្លាស្ទិចទៅជារៀងរាល់ថ្ងៃទេ » ។

« ពិតមែនឬម៉ាក់ ? » សូហ្វៀបានសួរ ។

ម៉ាក់បានងក់ក្បាល ។ « ចាសកូន ។ គ្រាន់តែសុំឲ្យនាងថែរក្សាវាឲ្យគង់ទៅបានហើយ » ។

សូហ្វៀបានយកដបទឹកទៅសាលារៀន ។ រឿងទីមួយដែលនាងធ្វើពេលដល់សាលា គឺឲ្យដបទឹកទៅខាឌី ។

ខាឌីបានលាន់មាត់ថា « អស្ចារ្យណាស់ » ។ « អរគុណសូហ្វៀ » ។ ខាឌីបានឱបនាងយ៉ាងណែន ។

សូហ្វៀមានអារម្មណ៍កក់ក្ដៅនៅក្នុងចិត្ត ។ នាងបានដឹងថានាងបានជួយមិត្តរបស់នាងដូចជាព្រះយេស៊ូវដែរ ។●



តើអ្នកបានជួយនរណាម្នាក់ដោយរបៀបណា ?